ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ...១៨២៤៧...អពដ

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៦

# សេចក្តីជូនដំណឹង
## ស្តីពី
## ការពន្យារពេលលើកទី២ ការបង់ពន្ធលើអចលនទ្រព្យ សម្រាប់ឆ្នាំ២០១៦ រហូតដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦

អគ្គនាយកដ្ឋានពន្ធដារមានកិត្តិយសសូមជម្រាបជូនម្ចាស់អចលនទ្រព្យទាំងអស់ ដែលមានអចលនទ្រព្យស្ថិតក្នុងភូមិសាស្ត្រត្រូវជាប់ពន្ធលើអចលនទ្រព្យនៅរាជធានី-ខេត្ត ទូទាំងព្រះរាជាណាចក្រកម្ពុជាមេត្តាជ្រាបថា អគ្គនាយកដ្ឋានពន្ធដារពិនិត្យឃើញថា ក្នុងអំឡុងពេលនៃការពន្យារការប្រកាសបង់ពន្ធលើអចលនទ្រព្យរហូតដល់ថ្ងៃទី៣១ ខែតុលានេះ មានម្ចាស់អចលនទ្រព្យជាច្រើនកំពុងមមាញឹកមកប្រកាសបង់ពន្ធ ខណៈដែលមានម្ចាស់អចលនទ្រព្យមួយចំនួនទៀត ក៏នៅមិនទាន់បានមកប្រកាសបង់ពន្ធប្រភេទនេះ នៅឡើយ។

ដើម្បីបង្កលក្ខណៈងាយស្រួល និងផ្តល់លទ្ធភាពជូនម្ចាស់អចលនទ្រព្យដែលមិនទាន់បានមកប្រកាសបង់ពន្ធ មានពេលវេលាគ្រប់គ្រាន់ក្នុងការមកប្រកាសបង់ពន្ធនេះ អគ្គនាយកដ្ឋានពន្ធដារសម្រេចពន្យារពេលនៃការប្រកាសបង់ពន្ធលើអចលនទ្រព្យសម្រាប់ឆ្នាំ២០១៦ ជាលើកទីពីរ រហូតដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦។ ម្ចាស់អចលនទ្រព្យទាំងឡាយណាដែលមិនមកប្រកាសបង់ពន្ធក្នុងអំឡុងពេល ឬក្រោយការពន្យារពេលខាងលើនេះ នឹងត្រូវទទួលរងនូវទោសទណ្ឌស្របតាមច្បាប់ស្តីពីសារពើពន្ធ ជាធរមាន។

អគ្គនាយកដ្ឋានពន្ធដារមានក្តីសង្ឃឹមយ៉ាងមុតមាំថា ក្នុងអំឡុងពេលនៃការពន្យារការបង់ពន្ធប្រភេទនេះ ម្ចាស់អចលនទ្រព្យទាំងអស់នឹងប្រូសរាន់មកប្រកាសបង់ពន្ធបានទាន់ពេលវេលា តាមការកំណត់នេះជាក់ជាពុំខាន។

Collection by VCAT Professional Consultant

ប្រតិភូរាជរដ្ឋាភិបាល
ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ

គង់ វិបុល